**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...០០១.៣៧...... ក.ប/ខ.ល

# សារលិខិតជូនពរ

## សូមគោរពជូនពរ

## សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

*សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*

នាឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយទឹកចិត្តសោមនស្សរីករាយយ៉ាងក្រៃលែង នៃពិធីចម្រើនជន្មាយុ ៧៨ឆ្នាំ ឈានចូល ៧៩ឆ្នាំ នាថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងសូមប្រសិទ្ធពរបវរមហាប្រសើរជូនដល់ **សម្តេចវិបុលសេនាភក្តី** ទទួលបាននូវប្រាជ្ញាឈ្លាសវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ និងសម្រេចបាននូវជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់សម្តេច ចំពោះប្រជាជន និងប្រទេសជាតិ។

យើងខ្ញុំសូមយកឱកាសដ៏វិសេសវិសាលនេះ សម្តែងនូវមនោសញ្ចេតនាគោរពស្រលាញ់ កោតសរសើរដោយស្មោះអស់ពីដួងចិត្ត និងចងចាំជានិច្ចនូវគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី** ដែលបានលះបង់កម្លាំងកាយចិត្ត ពេលវេលា និងបញ្ញាញាណ ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាជនកម្ពុជាក្នុងការដឹកនាំព្រឹទ្ធសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការពង្រឹងនីតិរដ្ឋ លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ក៏ដូចជាការលើកកម្ពស់វិស័យសន្តិសុខ និងសុវត្ថិភាពសង្គម ព្រមទាំងបានបំពេញតួនាទីប្រកបដោយមនុស្សធម៌ កសាងនូវសមិទ្ធផលជាច្រើនទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ដើម្បីទុកជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសដ៏មង្គលាភិរម្យនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមជួយបីបាច់ថែរក្សា និងប្រោះព្រំសព្ទសាធុការពរ បវរសួស្តី សិរីមង្គលវិបុលសុខ មហាប្រសើរជូន **សម្តេចវិបុលសេនាភក្តី** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រលាញ់ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ សុក្រ ៨រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩